**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៩..សសរ...

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពនៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១០/០០៩ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២៥៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា (គ.ស.ន.ម.ក.) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តមនាយឧត្តមសេនីយ៍ **អ៊ុក គឹមលេខ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឯកឧត្តម **ឈួន សុធី** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- ឯកឧត្តម **ចាន់ តារា** | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិក |
| ៦- ឯកឧត្តម **ឡុង សារាវុធ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ៧- ឯកឧត្តម **ស៊ិន រុន** | អភិបាលរងខេត្តសៀមរាប | សមាជិក |
| ៨- ឯកឧត្តម **ចេង ញ៉ាន់** | អភិបាលរងខេត្តកំពង់ឆ្នាំង | សមាជិក |
| ៩- លោក **សំរិទ្ធ សាកុរ៉ា** | អគ្គនាយករងពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- លោក **ម៉ៅ ផល្លា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១១- លោក **ហ៊ុយ តីរក្ស** | អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១២- ឧត្តមនាវីឯក **មាន ទ៉ា** | មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងទឹក នៃក្រសួងការពារជាតិ | សមាជិក |
| ១៣- លោកវេជ្ជបណ្ឌិត **លី សូវ៉ាន់** | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃក្រសួងសុខាភិបាល | សមាជិក |
| ១៤- លោក **ឡុង សុខន** | អនុប្រធាននាយកដ្ឋានអង្គការអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥- លោក **ហេង សុថារិទ្ធ** | អនុប្រធាននាយកដ្ឋានកិច្ចការជលផលនៃរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៦- លោក **សេង ពុទ្ធី** | អនុប្រធាននាយកដ្ឋានក្រសួងយុត្តិធម៌ | សមាជិក |
| ១៧- លោក **តិន រ៉ាឌី** | ប្រធានការិយាល័យគ្រប់គ្រងគុណភាពទឹកនិងដីនៃនាយកដ្ឋាន ត្រួតពិនិត្យការបំពុលបរិស្ថាននៃក្រសួងបរិស្ថាន | សមាជិក |
| ១៨- លោក **សុខ ដារ៉ាទី** | អនុប្រធានការិយាល័យគ្រប់គ្រងច្រាំងទន្លេនៃនាយកដ្ឋានជលសាស្ត្រ និងការងារទន្លេនៃក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១៩- លោក **ហ្វូត ហៃ** | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ២០- លោក **ខ័ណ្ឌ ចំណាន** | អភិបាលរងខេត្តក្រចេះ | សមាជិក |
| ២១- លោក **កែវ នារុទ្ធិ** | នាយករងរដ្ឋបាលសាលាខេត្តកំពង់ចាម | សមាជិក |
| ២២- លោកស្រី **អេង សោភា** | ប្រធានការិយាល័យកិច្ចការសេដ្ឋកិច្ចនិងសង្គមកិច្ច នៃសាលាខេត្តស្ទឹងត្រែង | សមាជិក |
| ២៣- លោក **ប៉ាន នារៈ** | ប្រធានការិយាល័យនៃសាលាខេត្តតាកែវ | សមាជិក |
| ២៤- លោក **ចាន់ សុភាព** | មន្ត្រីការិយាល័យកិច្ចការច្បាប់និងសុវត្ថិភាពសាធារណៈ នៃសាលាខេត្តកណ្តាល | សមាជិក |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ